# សុន្ទរកថា
# ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន
# ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
# ថ្លែងក្នុង
# ពិធីសម្ពោធជាផ្លូវការ "មជ្ឈមណ្ឌលអាស៊ានសម្រាប់ការអប់រំឌីជីថល"

ថ្ងៃ អង្គារ ៨ កើត ខែ កត្តិក ឆ្នាំ ខាល ចត្វាស័ក ព.ស. ២៥៦៦

ថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០២២

- ***ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា;***
- ***ឯកឧត្តម*** *Dato Lim Jock Hoi* ***អគ្គលេខាធិការអាស៊ាន;***
- ***ឯកឧត្តម, លោកជំទាវ, ឯកអគ្គរាជទូត, ឯកអគ្គរដ្ឋទូត, តំណាងស្ថានទូតនៃប្រទេសជាសមាជិកអាស៊ាន;***
- ***ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី;***
- ***លោកគ្រូ, អ្នកគ្រូ, ក្មួយៗសិស្សានុសិស្ស, អង្គពិធីទាំងមូលជាទីមេត្រី!***

ថ្ងៃនេះ, ខ្ញុំពិតជាមានសេចក្តីសោមនស្សជាអនេក ដោយបានចូលរួមជាអធិបតី ក្នុងពិធីសម្ពោធជាផ្លូវការ **"មជ្ឈមណ្ឌលអាស៊ានសម្រាប់ការអប់រំឌីជីថល"** នៅក្នុងបរិវេណនៃវិទ្យាល័យព្រះស៊ីសុវត្ថិ នៃរាជធានីភ្នំពេញ ។

យោងលើសុន្ទរកថាស្វាគមន៍របស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**, ខ្ញុំសូមសម្តែងការអបអរសាទរ និងកោតសរសើរដ៏ស្មោះ ចំពោះ **ឯកឧត្តមរដ្ឋមន្ត្រី**, ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជននិងកីឡា, ព្រមទាំងសហការី, ដែលបានដឹកនាំរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាសហគមន៍សង្គម-វប្បធម៌អាស៊ាន **លើកទី ២៨** កាលពីថ្ងៃទី **១៣ ខែ តុលា ឆ្នាំ ២០២២**

ប្រកបដោយជោគជ័យ ។ កិច្ចប្រជុំបានអនុម័ត និង កត់សម្គាល់ឯកសារលទ្ធផល ចំនួន ៣១ ដោយរួមមាន "**សេចក្តីថ្លែងការណ៍ស្តីពីបរិវត្តកម្មឌីជីថលនៃប្រព័ន្ធអប់រំក្នុងតំបន់អាស៊ាន**" និង គំនិតផ្តួចផ្តើមរបស់កម្ពុជាលើសេចក្តីណែនាំអំពី "**ការបើកឡើងវិញ, ការងើបឡើងវិញ និង ភាពធន់ក្នុងវិស័យអប់រំ៖ សេចក្តីណែនាំសម្រាប់ប្រទេសអាស៊ាន**" ដើម្បីធានាថា កុមារ និង យុវជនទាំងអស់នឹងទទួលបានការអប់រំប្រកបដោយគុណភាព និង សុវត្ថិភាព ។

កម្ពុជា មិនខុសពីប្រទេសដទៃទៀតក្នុងពិភពលោកឡើយ, បានជួបប្រឈមនឹងការរាតត្បាត និង ផលប៉ះពាល់ជាអវិជ្ជមានពីជំងឺកូវីដ-១៩ ដែលមិនត្រឹមតែបានឆក់យកជីវិតប្រជាជនប៉ុណ្ណោះទេ; ប៉ុន្តែ ថែមទាំងដាក់សម្ពាធលើប្រភពកំណើន និង បង្កើតជាបច្ច័យអវិជ្ជមានដល់សកម្មភាពសង្គម-សេដ្ឋកិច្ចមួយផ្នែកធំផងដែរ ។ ជាក់ស្តែង, សេដ្ឋកិច្ចកម្ពុជា បានប្រឈមនឹងកំណើនអវិជ្ជមានជាលើកដំបូង បន្ទាប់ពីវិបត្តិហិរញ្ញវត្ថុសកលឆ្នាំ ២០០៨-២០០៩ ដែលកាលនោះ កំណើនបានធ្លាក់មកនៅកម្រិតលើសូន្យបន្តិច ប៉ុណ្ណោះ។ ជាមួយគ្នានេះ, ការអប់រំត្រូវបានរងផលប៉ះពាល់យ៉ាងខ្លាំង ដោយសាលារៀនត្រូវបង្ខំចិត្តបិទទ្វារ ហើយការរៀន និង ការបង្រៀនត្រូវបានផ្លាស់ប្តូរទាំងស្រុងពីការរៀន និង ការបង្រៀននៅក្នុងថ្នាក់ផ្ទាល់ មកជាការរៀន និង ការបង្រៀនពីចម្ងាយ ដែលត្រូវការបច្ចេកវិទ្យាឌីជីថលជាជំនួយដ៏ចាំបាច់ខានមិនបាន ។ ការអនុវត្តដោយជោគជ័យនូវយុទ្ធនាការជាតិចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ របស់រាជរដ្ឋាភិបាលបានធ្វើឱ្យកម្ពុជាមានលទ្ធភាពបើកប្រទេស និង សង្គម-សេដ្ឋកិច្ច ពេញលេញឡើងវិញ ព្រមទាំងបានអនុញ្ញាតឱ្យប្រជាជនកម្ពុជាអាចធ្វើការងារ និង ប្រកបអាជីវកម្មផ្សេងៗ, លោកគ្រូ អ្នកគ្រូអាចបង្រៀនដោយផ្ទាល់, ហើយក្មួយៗសិស្សានុសិស្សក៏អាចវិលត្រលប់មកសាលារៀនបានជាធម្មតាវិញផងដែរ ។

*- ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី;*

*-លោកគ្រូ, អ្នកគ្រូ, ក្មួយៗសិស្សានុសិស្ស, អង្គពិធីទាំងមូល ជាទីមេត្រី!*

នៅក្នុងស្ថានភាពដ៏ស្រួចស្រាល់នៃការរាតត្បាតជំងឺកូវីដ-១៩, ជាងពេលណាៗផ្សេងទៀត, បច្ចេកវិទ្យាឌីជីថលបានដើរតួនាទីកាន់តែសំខាន់ក្នុងការបង្កើនផលិតភាព, ក៏ដូចជាការជំរុញពិពិធកម្មសេដ្ឋកិច្ច និង ការបង្កើតការងារ សំដៅជំរុញវឌ្ឍនភាពសង្គម-សេដ្ឋកិច្ចឱ្យកាន់តែរីកចម្រើនថែមទៀត ព្រមទាំងបាន និង កំពុងផ្លាស់ប្តូរទម្លាប់រស់នៅ និងជីវិតប្រចាំថ្ងៃរបស់យើង ។ បច្ចេកវិទ្យាទាំងនេះ ក៏បាន និង កំពុងបង្កើនប្រសិទ្ធភាពក្នុងដំណើរការរៀន និង បង្រៀន, ការ-

ប្រាស្រ័យទាក់ទងគ្នា, ការស្វែងរកការងារ, និង ការពង្រឹងប្រសិទ្ធភាពការងារ, ព្រមទាំងបាន និង កំពុងជំរុញការបង្កើតនូវគំនិតច្នៃប្រឌិតបន្ថែមទៀត ផងដែរ ។

ដោយមើលឃើញពីសក្តានុពលនេះ, រាជរដ្ឋាភិបាលបានដាក់ចេញឱ្យអនុវត្តនូវ "**ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥**" កាលពីឆ្នាំ ២០២១, ដែលជាក្របខណ្ឌរួម និងជាផែនទីចង្អុលផ្លូវ ក្នុងគោលដៅជំរុញដំណើរការបរិវត្តកម្មឌីជីថល លើគ្រប់តួអង្គ ក្នុងសេដ្ឋកិច្ច និងសង្គមជាតិកម្ពុជាទាំងមូល ។ ក្របខណ្ឌគោលនយោបាយនេះ មានសសរស្តម្ភចំនួន ៣ គឺ៖ ទី១-ការកសាងរដ្ឋាភិបាលឌីជីថល; ទី២-ការកសាងធុរកិច្ចឌីជីថល; និង ទី៣-ការកសាងពលរដ្ឋឌីជីថល ។ ការកសាងពលរដ្ឋឌីជីថល, ទាំងផ្នែកអក្ខរកម្ម និង សមត្ថភាព, (Digital Literacy and Digital Capability) ជាកិច្ចការមួយដ៏មានសារៈសំខាន់បំផុត ដែលត្រូវការពេល និង ធនធាន ដើម្បីធានានូវការចូលរួមពេញលេញរបស់ប្រជាជនក្នុងសង្គមឌីជីថលមួយដែលរស់រវើក ប្រកបដោយបរិយាប័ន្ន និង ប្រកបដោយសុវត្ថិភាព។ នៅក្នុងក្របខណ្ឌនេះ, ក្រសួងអប់រំ យុវជន និងកីឡា មានតួនាទីគន្លឹះ ក្នុងការជួយធ្វើឱ្យសសរស្តម្ភនៃការកសាងពលរដ្ឋឌីជីថល មានភាពរឹងមាំ និង មានគុណភាព ។

ជាមួយនឹងការទទួលស្គាល់នូវភាពឆាប់រហ័ស និង ផលប្រយោជន៍នៃល្បឿនបរិវត្តកម្មឌីជីថលក្នុងវិស័យសង្គម-សេដ្ឋកិច្ចនាជំណាក់កាលចុងក្រោយនេះ, ជាពិសេសនៅក្នុងវិស័យអប់រំ, យើងក៏ត្រូវចាប់អារម្មណ៍ និង ងាកទៅមើលលើផលវិបាកដោយផ្ទាល់ និង ប្រយោលនៃការចាប់យកបច្ចេកវិទ្យាឌីជីថល ពីសំណាក់សិស្សានុសិស្ស, គ្រូបង្រៀន, និង គណៈគ្រប់គ្រងសាលារៀន ដើម្បីកាត់បន្ថយគម្លាតឌីជីថល និង ហានិភ័យអនឡាញ (Online Risk) ផងដែរ ។ កម្រិតជាមូលដ្ឋាននៃអក្ខរកម្មឌីជីថល គប្បីត្រូវបានលើកឱ្យខ្ពស់ជាងមុន ដើម្បីបង្កើនភាពត្រៀមខ្លួនរួចជាស្រេចនៃធនធានមនុស្សដែលត្រូវបានផលិតចេញពីវិស័យអប់រំ ឱ្យក្លាយជាពលរដ្ឋឌីជីថលពេញលេញ ។ ហេតុដូចនេះ, សិស្សានុសិស្ស និង គ្រូបង្រៀន ត្រូវភ្ជាប់ខ្លួនទៅកាន់នវានុវត្តន៍នៃការអប់រំថ្មីៗ; មាតិកាឌីជីថល និង កម្មវិធីសិក្សាដែលសម្បូរបែប និង មានគុណភាព; បណ្តាញគ្រឹះស្ថានសិក្សាដែលមានម៉ូដែល និង គំរូថ្មីៗ; ឱកាសសម្រាប់អភិវឌ្ឍបំណិនសតវត្សទី ២១ ឱ្យបានកាន់តែប្រសើរ; និង ត្រូវផ្សារភ្ជាប់ការសិក្សាទៅកាន់តម្រូវការនៅលើទីផ្សារការងារ ដែលតម្រូវឱ្យមានសមត្ថភាព និង ជំនាញឌីជីថលកាន់តែខ្ពស់ ។

ក្នុងន័យនេះ, ការសម្ពោធ "**មជ្ឈមណ្ឌលអាស៊ានសម្រាប់ការអប់រំឌីជីថល**" នៅថ្ងៃនេះ បានឆ្លុះបង្ហាញយ៉ាងប្រត្យក្សនូវកិច្ចខិតខំប្រឹងប្រែង និង ការឆ្លើយតបរបស់រាជរដ្ឋាភិបាលកម្ពុជាតាមរយៈក្រសួងអប់រំ យុវជន និង កីឡា ក្នុងការពន្លឿនបរិវត្តកម្មឌីជីថលនៅក្នុងប្រព័ន្ធអេកូឡូស៊ីនៃការ

អប់រំ; ការបង្កិតបច្ចេកវិទ្យាអប់រំឱ្យបានដល់ដៃសិស្សានុសិស្ស; ការច្បាមយកកាលានុវត្តភាពនៃនវានុវត្តន៍ផ្នែកបច្ចេកវិទ្យាសម្រាប់ការអប់រំ; និង ការជំរុញភាពឈានមុខរបស់កម្ពុជានៅក្នុងកម្រិតតំបន់ លើដំណើរសមាហរណកម្មនៃបច្ចេកវិទ្យាអប់រំ ។ ខ្ញុំសូមគូសបញ្ជាក់បន្ថែមថា ការអប់រំកំពុងត្រូវផ្លាស់ប្តូរមុខមាត់ថ្មី តាមរយៈបរិវត្តកម្មនៃការអប់រំ ក្នុងពេលដែលការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថលកំពុងមានតម្រូវការផ្នែកជំនាញ និង ទេពកោសល្យ ហើយអ្នកសិក្សាត្រូវតែបន្តរៀនជាប់ជាប្រចាំនូវជំនាញថ្មីៗ, ត្រូវបន្សាំខ្លួនជាមួយនឹងប្រព័ន្ធអេកូឡូស៊ីការងារដែលមានការប្រែប្រួលជាប់ជាប្រចាំ, និង ត្រូវបណ្តុះគំនិតច្នៃប្រឌិតសម្រាប់ដឹកនាំឱ្យមានបរិវត្តកម្មឌីជីថល ។ ចាប់ពីពេលនេះទៅ, ការអប់រំនៅគ្រប់កម្រិតនឹងត្រូវ **"រំកិលពីការបង្រៀនសិស្សពីសំណួរថា តើត្រូវរៀនអ្វីខ្លះ? ទៅកាន់សំណួរថា តើត្រូវរៀនដោយវិធីសាស្ត្រណា?"** ។ ពិធីនៅថ្ងៃនេះ ក៏បង្ហាញពីការប្តេជ្ញាចិត្តរបស់កម្ពុជា ក្នុងការចូលរួមសម្រេចឱ្យបាននូវ "The Bandar Seri Begawan Roadmap 2021-2025" ដែលជារបៀបវារៈបរិវត្តកម្មឌីជីថលអាស៊ាន ដើម្បីពន្លឿនការងើបឡើងវិញនៃសេដ្ឋកិច្ច និង សមាហរណកម្មសេដ្ឋកិច្ចឌីជីថលផងដែរ ។

- ***ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី;***

- ***លោកគ្រូ, អ្នកគ្រូ, ក្មួយៗសិស្សានុសិស្ស, អង្គពិធីទាំងមូល ជាទីមេត្រី!***

ដើម្បីជាធាតុចូលសម្រាប់ពិធីសម្ពោធជាផ្លូវការនូវ **"មជ្ឈមណ្ឌលអាស៊ានសម្រាប់ការអប់រំឌីជីថល"** ក្នុងពេលនេះ, ខ្ញុំសូមលើកឡើងនូវចំណុចចំនួន ៦ ដូចតទៅ៖

ទី១ )- **ការបន្តលើកកម្ពស់អក្ខរកម្មឌីជីថលជាទូទៅ** (Digital Literacy)៖ ការផ្តល់ការអប់រំផ្នែកបច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍ និង ការយល់ដឹងពីការប្រើប្រាស់បច្ចេកវិទ្យា និង ឧបករណ៍ឌីជីថលជាទូទៅ សម្រាប់ការរៀន, ការធ្វើការ, ការធ្វើអាជីវកម្ម, និង ហានិភ័យអនឡាញសម្រាប់សិស្សានុសិស្ស គួរត្រូវបានបន្ថែម និង កែលម្អ ដោយដាក់បញ្ចូលចាប់តាំងពីកម្រិតមធ្យមសិក្សា ក្នុងគោលដៅបង្រួមគម្លាតឌីជីថលឱ្យកាន់តែតូច ។

ទី២ )- **ការពង្រឹងការអភិវឌ្ឍសមត្ថភាព និង ជំនាញឌីជីថល** (Digital Skill and Capabilities) ដោយផ្តោតលើការកែទម្រង់នៃការអប់រំក្នុងកម្រិតឧត្តមសិក្សា និង ការកែសម្រួលកម្មវិធីសិក្សាផ្នែកឌីជីថល និង វិទ្យាសាស្ត្រកុំព្យូទ័រ, ជាពិសេសការដាក់បញ្ចូលនូវមុខវិជ្ជាតម្រូវ, មានជាអាទិ៍ តក្កកម្មបរិមាណ (Quantitative Reasoning) និង ការគិតបែបគណនា (Computational Thinking) ឱ្យកាន់តែល្អប្រសើរ ដែលអាចបង្កើតនូវសមត្ថភាព និង ជំនាញឌីជីថល ច្បាស់លាស់, មានគុណភាព, និង ឆ្លើយតបទៅនឹងទីផ្សារការងារបច្ចុប្បន្ន និង អនាគត

កិច្ចការនេះគប្បីត្រូវបានគិតគូរទាំងកម្រិតនៃការធ្វើផែនការ ឬ យុទ្ធសាស្ត្រ និង កម្រិតការអនុវត្ត ផងដែរ ។

ទី៣)- **ការពង្រីកតួនាទីរបស់សាកលវិទ្យាល័យ និង ការអប់រំនៅកម្រិតឧត្តមសិក្សា៖** នៅក្នុងបរិបទនៃបដិវត្តន៍ឧស្សាហកម្មទី ៤, សាកលវិទ្យាល័យគួរដើរតួនាទី មិនត្រឹមតែក្នុងការរៀន, ការបង្រៀន និង ការស្រាវជ្រាវប៉ុណ្ណោះទេ ។ ប៉ុន្តែ, លើសពីនេះ, ការជំរុញ និង ការលើកកម្ពស់អនាគតនៃសហគ្រិនភាព និង ការបង្កើតធុរកិច្ចថ្មី នៅតាមសាកលវិទ្យាល័យ ក៏ជានិន្នាការសាកលដែលយើងមិនត្រូវមើលរំលងឡើយ។ ក្នុងន័យនេះ, ខ្ញុំសូមលើកទឹកចិត្តឱ្យក្រសួងអប់រំ យុវជន និង កីឡា, រួមជាមួយនឹងគ្រឹះស្ថានឧត្តមសិក្សាទាំងអស់, សហការជាមួយនឹងស្ថាប័ន និងអង្គភាពដែលធ្វើកិច្ចការនេះដោយផ្ទាល់ ដូចជា **មជ្ឈមណ្ឌលបណ្ដុះធុរកិច្ចថ្មី "តេជោ" និង សហគ្រិនខ្មែរ** ជាដើម ដើម្បីបង្កើតជាសហថាមពល (Synergy) ក្នុងការជំរុញ និង លើកកម្ពស់បំណិនសហគ្រិន និង ការធ្វើធុរកិច្ចថ្មី នៅតាមគ្រឹះស្ថានឧត្តមសិក្សា ។

ទី៤)- **ការបន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និង ថ្នាលឌីជីថល ដែលគាំទ្រដល់ការអប់រំឌីជីថល៖** ជាការពិត, ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានផ្ដល់អាទិភាព និង ថវិកាជាបន្តបន្ទាប់ ជូនក្រសួងអប់រំ យុវជន និងកីឡា ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដើម្បីចូលរួមដល់បេសកកម្មនៃការជំរុញឌីជីថលូបនីយកម្មនៅក្នុងវិស័យអប់រំ ដែលមជ្ឈមណ្ឌលនេះ ជាសក្ខីភាពមួយនៃការវិនិយោគរបស់យើងកន្លងមក ។ ជាការគិតគូរទៅមុខ, ការវិនិយោគត្រូវផ្តោតទៅលើស្ថាប័ន និង គ្រឹះស្ថានសិក្សា ដែលមានសក្តានុពលខ្ពស់សម្រាប់ប្រព័ន្ធអេកូឡូស៊ីនៃការអប់រំឌីជីថល និងដែលផ្តល់លទ្ធផលខ្ពស់ ។ ការវិនិយោគនឹងត្រូវបានផ្តោតទៅលើកត្តាជំរុញ (Enabling Factors) ជាក់លាក់ ដែលនាំឱ្យមានបរិវត្តកម្មអប់រំ ជាអាទិ៍ ហេដ្ឋារចនាសម្ព័ន្ធ និង សម្ភារបច្ចេកវិទ្យា, វិធីសាស្ត្របង្រៀន, កម្មវិធីសិក្សា, វេទិកាឌីជីថល, និង ប្រព័ន្ធគ្រប់គ្រងការសិក្សា, ក៏ដូចជាកត្តារួមផ្សំដទៃទៀត រួមមាន ការតភ្ជាប់បណ្ដាញ, ការគ្រប់គ្រងទិន្នន័យ និង អ៊ីនធឺណិត ជាដើម ។

ទី៥)- **ការផ្សារភ្ជាប់បរិវត្តកម្មឌីជីថលនៃការអប់រំនៅកម្ពុជា** ទៅកាន់កម្រិតតំបន់, ជាពិសេសបណ្ដាប្រទេសជាសមាជិកអាស៊ាន, ដែលជាតួនាទីស្នូលនៃការបង្កើត "**មជ្ឈមណ្ឌលអាស៊ានសម្រាប់ការអប់រំឌីជីថល**" ។ តាមរយៈមជ្ឈមណ្ឌលនេះ, ទិន្នន័យនៃការអប់រំនឹងត្រូវបានប្រមូល និង ប្រើប្រាស់ សម្រាប់ការសម្រេចចិត្តផ្នែកគោលនយោបាយឱ្យកាន់តែប្រសើរ; ជម្រើសនៃការសិក្សារបស់សិស្ស នឹងត្រូវបានបង្កើនឱ្យកាន់តែសម្បូរបែប; ការដកស្រង់បទពិសោធ និងឧត្តមានុវត្តនៃការបង្រៀន និង ការគ្រប់គ្រងការអប់រំ នឹងត្រូវបានចែករំលែក ហើយមាតិកាឌីជីថលកាន់តែច្រើន នឹងត្រូវបានផលិត ។

ទី៦ )- **ការបន្តពង្រឹងប្រព័ន្ធអប់រំឱ្យមានភាពធន់ និង បុរេសកម្ម** ដើម្បីឆ្លើយតបទៅនឹងបរិការណ៍ជាតិ និង អន្តរជាតិ ដែលកំពុងមានការប្រែប្រួល ដោយសង្កត់ធ្ងន់លើការជំរុញបរិវត្ត-កម្មឌីជីថលនៅក្នុងការអប់រំ និង ការលើកកម្ពស់ការវិនិយោគលើការអប់រំវិទ្យាសាស្ត្រ និង បច្ចេក-វិទ្យា ។ ប្រការនេះ ក៏ទាមទារផងដែរ នូវការបន្តធានានូវសេវាអប់រំ ដែលមានគុណភាព, ប្រកបដោយសមធម៌ និង បរិយាប័ន្ន, ព្រមទាំងការលើកកម្ពស់ឱកាសការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ។

យ៉ាងណាមិញ, ខ្ញុំក៏សូមយកឱកាសនេះធ្វើការគូសរំលេចផងដែរថា ក្នុងខណៈដែលយើងទទួលស្គាល់ពីសារៈសំខាន់នៃបច្ចេកវិទ្យាឌីជីថល, បច្ចេកវិទ្យានេះគ្រាន់តែជាឧបករណ៍ដែលជួយឱ្យការរៀន និង ការបង្រៀនកាន់តែមានប្រសិទ្ធភាព ប៉ុណ្ណោះ; ប៉ុន្តែឧបករណ៍នេះនឹងមិនមែនជារបស់ដែលត្រូវយកមកជំនួយឱ្យការរៀន និង ការបង្រៀនដោយផ្ទាល់នោះបានទេ ដែលមានន័យថា "**បច្ចេកវិទ្យា គឺជាឧបករណ៍ជំនួយ, តែមិនមែនជាឧបករណ៍ជំនួស នោះឡើយ**" ។

- ***ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី;***

- ***លោកគ្រូ, អ្នកគ្រូ, ក្មួយៗសិស្សានុសិស្ស, អង្គពិធីទាំងមូល ជាទីមេត្រី!***

មុននឹងបញ្ចប់, ខ្ញុំសូមសម្តែងការកោតសរសើរដ៏ស្មោះចំពោះលោកគ្រូ-អ្នកគ្រូ ដែលបានខិតខំប្រឹងប្រែងកន្លងមក, ជាពិសេសក្នុងអំឡុងនៃវិបត្តិជំងឺកូវីដ-១៩, ក្នុងការធានានូវនិរន្តរភាពនៃការសិក្សារបស់សិស្សានុសិស្ស តាមរយៈការខិតខំប្រឹងប្រែងសិក្សាស្រាវជ្រាវ, ទាំងផ្នែកចំណេះ-ដឹង, និង ជំនាញឌីជីថល, ព្រមទាំងវិធីសាស្ត្របង្រៀនថ្មីៗ, ស្របទៅតាមបរិការណ៍សង្គម ។ គ្រូបង្រៀននឹងបន្តដើរតួជាបុគ្គលនាំមុខ, ជាមគ្គុទេសក៍, ជាអ្នកស្រាវជ្រាវ, ជាទីប្រឹក្សា, ជាឪពុកម្តាយទីពីរ, និង ជាអ្នកច្នៃប្រឌិត ។ ដូចនេះ, គ្រូបង្រៀនចាំបាច់ត្រូវខិតខំប្រឹងប្រែងអភិវឌ្ឍសមត្ថភាពរបស់ខ្លួនជាប្រចាំ, ទាំងផ្នែកចំណេះដឹង និង ជំនាញលើមុខវិជ្ជាឯកទេស, ការប្រើ-ប្រាស់បច្ចេកវិទ្យា, គរុកោសល្យថ្មីៗ, និង ភាសាបរទេស, ដើម្បីបង្ហាត់បង្ហាញដល់សិស្សានុសិស្សឱ្យមានចំណេះដឹងទូលំទូលាយ និង អភិវឌ្ឍខ្លួនទៅជាពលរដ្ឋសកល, ជាធនធានចន្លល់ដ៏សំខាន់ក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ, និង ជាអ្នកបន្តវេនសម្រាប់អនាគត ។

**ក្នុងនាមរាជរដ្ឋាភិបាល និង ក្នុងនាមខ្លួនខ្ញុំផ្ទាល់, ខ្ញុំសូមថ្លែងអំណរគុណម្តងទៀត ចំពោះថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និង កីឡា, បុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់, ដៃគូអភិវឌ្ឍន៍ជាតិ និង អន្តរជាតិ, វិស័យឯកជន, ព្រមទាំងសហគមន៍ទាំងអស់, ដែលបានសហការ និង ចូលរួមគាំទ្រយ៉ាងសកម្ម ដល់ការអភិវឌ្ឍវិស័យអប់រំនៅកម្ពុជា ប្រកបដោយជោគជ័យ ក្នុងឆ្នាំសិក្សាកន្លងមក**

និង សូមលើកទឹកចិត្តឱ្យបន្តការគាំទ្រ និង ស្មារតីចូលរួមនេះតទៅមុខទៀត ដើម្បីជាឧត្តមប្រយោជន៍ដល់កុមារ និង យុវជនកម្ពុជាគ្រប់រូប ។

ខ្ញុំសូមជូនពរ ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, លោកគ្រូ, អ្នកគ្រូ, ក្មួយៗសិស្សានុសិស្សទាំងអស់, សូមសមប្រកបដោយពុទ្ធពរទាំង ៤ ប្រការ គឺ អាយុ, វណ្ណៈ, សុខៈ, ពលៈ, កុំបីឃ្លៀងឃ្លាតឡើយ ។

ជាទីបញ្ចប់, ខ្ញុំសូមអបអរសាទរជាថ្មីម្តងទៀត ចំពោះការបង្កើត **"មជ្ឈមណ្ឌលអាស៊ានសម្រាប់ការអប់រំឌីជីថល"** និង ជាពិសេសចំពោះការដឹកនាំប្រកបដោយប្រសិទ្ធភាពនូវបរិវត្តកម្មឌីជីថលនៅក្នុងការអប់រំ របស់ក្រសួងអប់រំ យុវជន និង កីឡា ។

ខ្ញុំមានកិត្តិយសសូមប្រកាសសម្ពោធជាផ្លូវការនូវ **"មជ្ឈមណ្ឌលអាស៊ានសម្រាប់ការអប់រំឌីជីថល"** ចាប់ពីពេលនេះតទៅ ៕

*សូមអរគុណ!*